ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា

ប្រចាំប្រទេសជប៉ុន

តូក្យូ, ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥

លេខ: ១៦ /១៥ តក

**សូមគោរពជូន**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ**

**កម្មវត្ថុ:** ស្ថានភាពសេដ្ឋកិច្ចជប៉ុន និងសកម្មភាពការងារទីប្រឹក្សាពាណិជ្ជកម្មប្រចាំខែកុម្ភៈ-មីនា២០១៥។

ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបអំពីស្ថានភាពសេដ្ឋកិច្ច និងសកម្មភាពការងារទីប្រឹក្សាពាណិជ្ជកម្មប្រចាំខែកុម្ភៈ-មីនា ២០១៥ ដូចខាងក្រោម**:**

**១-ស្ថានការណ៍សេដ្ឋកិច្ច:**

**ក-សេដ្ឋកិច្ចជប៉ុន :**

នៅខែមីនា ២០១៥នេះ រដ្ឋាភិបាលជប៉ុន បានចេញផ្សាយនូវការកែសម្រួលអត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំនៅត្រីមាសទី៤ ឆ្នាំ២០១៤ កើនបាន 1.5% ដែលទាបជាងការព្យាករណ៍ ដែលថានឹងមានកំណើន 2.2%។ ការធ្លាក់ចុះនៃកំណើន GDP ដោយសារតែការបន្តទទួលរងនូវឥទ្ធិពលពីការដំឡើងពន្ធ VAT កាលពីឆ្នាំមុន និងការធ្លាក់ចុះការវិនិយោគក្នុងរយៈពេលបីត្រីមាសជាប់គ្នាៗ។

សម្រាប់ឆ្នាំ២០១៥ អង្គការ Organization for Economic Cooperation and Development (OECD) បានធ្វើការព្យាករណ៍កំណើនសេដ្ឋកិច្ចប្រទេសជប៉ុនថា នឹងកើនបាន 1% នៅឆ្នាំ២០១៥ និង 1.4% នៅឆ្នាំ ២០១៦ ដែលទិន្នន័យកំណើននេះ ត្រូវបានកែសម្រួលពីការព្យាករណ៍កាលពីខែវិច្ឆិកា ២០១៤ ថានឹងទទួលបានត្រឹមតែ 0.8% នៅឆ្នាំ ២០១៥ និង 1% នៅឆ្នាំ២០១៦ ដោយផ្អែកលើមូលដ្ឋានកំណើននៃតម្រូវការ (Demand) គួបផ្សំនឹងការធ្លាក់ថ្លៃប្រេង, ការបន្តអនុវត្តនយោបាយ Fiscal Stimulus Package និងការអនុវត្តនយោបាយ Monetary Easing Measures របស់ធនាគាររដ្ឋាភិបាល។

ជាមួយគ្នានេះដែរ ដើម្បីសម្រេចបាននូវផលពីនយោបាយ "Abenomics" រដ្ឋាភិបាលជប៉ុន បានបញ្ចុះបញ្ចូលឲ្យបណ្តាវិស័យឯកជនដំឡើងបៀវត្សជូននិយោជិករបស់ខ្លួន។ រហូតមកទល់ពេលនេះ មានក្រុមហ៊ុនធំៗជប៉ុនជាច្រើន បានប្រកាសពីការដំឡើងប្រាក់ឈ្នួលជូននិយោជិករបស់ខ្លួន បន្ទាប់ពីការឡើងថ្លៃទំនិញ។

នៅក្នុងខែមីនានេះដែរ រដ្ឋាបាលរបស់នាយករដ្ឋមន្ត្រី Shinzo Abe បានអនុម័តលើច្បាប់ពីរ: គឺ**ច្បាប់ស្តីពីការកែទម្រង់ពន្ធ២០១៥** ដែលបានកាត់បន្ថយពន្ធ National Corporate Tax ពីអត្រា 25.5% មកនៅអត្រា 23.9% និងកាត់បន្ថយពន្ធ Effective Corporate Tax ពីអត្រា 34.62% មកនៅអត្រា 32.11% និងបញ្ចុះអត្រាពន្ធចំណូលសហគ្រាសក្នុងស្រុក (Local Enterprise Tax Rate applicable to Income base) ពីអត្រា 7.2% មកនៅអត្រា 6% ដែលចាប់អនុវត្តពីថ្ងៃទី០១ ខែមេសា ២០១៥តទៅ និង**ច្បាប់ស្តីពីការបន្ធូរបន្ថយពន្ធដល់ក្រុមហ៊ុនផ្លាស់ការិយាល័យកណ្តាលរបស់ខ្លួនចេញពីទីក្រុងតូក្យូ** ក្នុងគោលបំណងជួយស្តារសេដ្ឋកិច្ចតំបន់ (Prefectures) ដែលច្បាប់ថ្មីនេះ នឹងផ្តល់ការបន្ថយពន្ធ 7% នៃចំនួនទឹកប្រាក់ដែលក្រុមហ៊ុនទាំងនោះចំណាយលើការសាងសង់ការិយាល័យថ្មីនៅខាងក្រៅទីក្រុងតូក្យូដោយមិនរាប់បញ្ចូលទីក្រុង OSAKA & NAGOYA។

***ខ-ស្ថានភាពប្រាក់យ៉េន (Source: Bank of Japan):***

***ខែមីនា ២០១៥:*** *អត្រាប្តូរប្រាក់យ៉េនទល់នឹងដុល្លាអាមេរិក ស្ថិតក្នុងរង្វង់ ¥119.12 ទៅ ¥119.71 /1ដុល្លារអាមេរិក។*

***គ-ស្ថានភាពការងារ (Source: Ministry of Internal Affairs & Communication of Japan):***

*យោងតាមទិន្នន័យការងាររបស់រដ្ឋាភិបាលជប៉ុនថ្ងៃទី២៧ ខែមីនា ២០១៥ បានបង្ហាញថា:*

*-អ្នកមានការងារធ្វើនៅក្នុងខែកុម្ភៈ ២០១៥នេះ មានចំនួន 63.22 លាននាក់ នៃកម្លាំងពលកម្មសរុប 65.48 លាននាក់ បានកើន 390,000នាក់ ឬ 0.6% បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៤។*

*-អ្នកគ្មានការងារធ្វើនៅក្នុងខែកុម្ភៈ ២០១៥នេះ មានចំនួន 2.26 លាននាក់ បានថយចុះ 60,000នាក់ ឬ 2.6% បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៤។*

*ដូច្នេះ អត្រាអ្នកគ្មានការងារធ្វើសម្រាប់ខែកុម្ភៈ ឆ្នាំ២០១៥នេះ គឺ 3.5%។*

***ឃ-សន្ទស្សន៍សេដ្ឋកិច្ច (Source: Bank of Japan):***

*ធនាគារកណ្តាលជប៉ុន បានចេញផ្សាយថ្ងៃទី១១ខែមីនា ២០១៥ នូវសន្ទស្សន៍ថ្លៃទំនិញសម្រាប់ខែកុម្ភៈ ២០១៥ មានដូចខាងក្រោម៖*

*-សន្ទស្សន៍ថ្លៃទំនិញ បានស្ថិតក្នុងសន្ទុះ 1.3% ដូចខែមករា*

*-សន្ទស្សន៍ថ្លៃនាំចេញ បានធ្លាក់ចុះ 0.8% ធៀបនឹងខែមករា*

*-សន្ទស្សន៍ថ្លៃនាំចូល បានធ្លាក់ចុះ 4.9% ធៀបនឹងខែមករា។*

***២-ស្ថានការណ៍ពាណិជ្ជកម្ម:***

***ក-ស្ថិតិពាណិជ្ជកម្មទ្វេភាគីជប៉ុន-កម្ពុជា:*** *(ខែកុម្ភៈ ២០១៥)*

*(Unit: 1,000Yen)*

| Activity | 2014 | | | 2015 | | 2 Mon. % change | Jan. -% Change |
|---|---|---|---|---|---|---|---|
| | 2014 | 2-months | February | 2-months | February | | |
| Export | 27,066,733 | 3,190,506 | 1,849,701 | 4,705,485 | 2,097,298 | 47.0 | 13.0 |
| Import | 81,620,826 | 11,481,517 | 6,229,433, | 18,566,929 | 9,140,168 | 62.0 | 47.0 |
| **Total** | 108,687,559 | 14,672,023 | 8,079,134 | 23,272,414 | 11,237,466 | 59.0 | 39.0 |
| **Balance** | **-54,554,093** | **-8,291,101** | **-4,379,732** | **-13,861,444** | **-7,042,870** | 67.0 | 61.0 |

*(Source: Ministry of Finance of Japan & Customs Office of Japan)*

*អតុល្យភាពជញ្ជីងពាណិជ្ជកម្មជប៉ុនក្នុងខែកុម្ភៈ ២០១៥ មានទំហំទឹកប្រាក់ ¥7,042.78 million ឬ $70.42 million បានកើន 67% ធៀបរយៈពេលដូចគ្នានៃឆ្នាំ២០១៤។ ទំហំពាណិជ្ជកម្មសរុប ជប៉ុន-កម្ពុជា មាន ¥11,237.46 million ឬ $112.37 million កើន 39% ដែលក្នុងនោះ ជប៉ុននាំចេញទៅកម្ពុជា ចំនួន ¥2,097.29 million ឬ $20.97 million កើន 13% និងនាំចូលពីកម្ពុជាចំនួន ¥9,140.16million ឬ $91.40 million កើន 47% ធៀបរយៈពេលដូចគ្នានៃឆ្នាំ២០១៤។*

*មុខទំនិញសំខាន់ៗ ជំរុញឲ្យមានកំណើនពាណិជ្ជកម្មជប៉ុន-កម្ពុជា គឺ (១)- ការនាំចេញពីជប៉ុន នូវមុខទំនិញដូចជា: រថយន្ត គ្រឿងចក្រ អេឡិចត្រូនិច ទំនិញឧស្សាហកម្ម វត្ថុធាតុដើមសម្រាប់ផលិតកម្មវាយនភ័ណ្ឌ-ស្បែកជើង និងទំនិញបន្ទាប់បន្សំផ្សេងៗទៀត និង(២)-ការនាំចូលពីកម្ពុជានូវមុខទំនិញ ដូចជា: ទំនិញវាយនភ័ណ្ឌ ស្បែកជើង គ្រឿងបង្គំរថយន្ត គ្រឿងអេឡិចត្រូនិច ត្បូង-ថ្មមានតម្លៃ និងផលិតផលផ្សេងៗទៀត។ល។*

### ខ-ស្ថិតិពាណិជ្ជកម្មជប៉ុន-អាស៊ាន: (ខែកុម្ភៈ ២០១៥)

**(Unit: Million of Yen)**

| Activity | January 2014 | January 2015 | Change % |
|---|---|---|---|
| Exports | 852,620 | 978,430 | 14.8 |
| Imports | 1,019,375 | 996,818 | -2.2 |
| Balance | 166,755 | 18,388 | -89.0 |
| Total Trade | 1,871,995 | 1,975,248 | 6.0 |

*(**Source**: Ministry of Finance of Japan & Customs Office of Japan)*

*ពាណិជ្ជកម្មជប៉ុន-អាស៊ានសរុបក្នុងខែកុម្ភៈ ២០១៥ មានទំហំ ¥1,975,248 million ឬ $19.75 billion បានកើនឡើង 6.0% ដែលការនាំចេញ កើន 14.8% និងការនាំចូលបានថយចុះ-2.2% និងមានឱនភាពពាណិជ្ជកម្ម ទំហំ ¥ 18,388 million ឬ$1.38billion បើធៀបនឹងខែកុម្ភៈ ២០១៤។ ទំហំពាណិជ្ជកម្មខាងលើនេះ បានថយចុះ 7.0% បើធៀបនឹងខែមករា២០១៥ ដែលមានទំហំទឹកប្រាក់ ¥2,122,338 million ។*

### គ-ស្ថិតិពាណិជ្ជកម្មជប៉ុន-ពិភពលោក: (ខែកុម្ភៈ ២០១៥)

| Activity | February 2014 | February 2015 | Change % |
|---|---|---|---|
| Exports | 5,799,170 | 5,941,062 | 2.4 |
| Imports | 6,605,299 | 6,365,660 | -3.6 |
| Balance | 806,129 | 424,598 | -47.3 |
| Total Trade | 12,404,299 | 12,306,722 | 1.0 |

*(**Source**: Ministry of Finance of Japan & Customs Office of Japan)*

*ឱនភាពពាណិជ្ជកម្មរបស់ជប៉ុនសម្រាប់ខែកុម្ភៈនេះ បានកើន 47.3% ស្មើ ¥424.59 billion ដែលឱនភាពនេះ មានទំហំតូចជាងឱនភាពកាលពីខែមករា២០១៥ ដែលមាន ¥1,177.46 billion។ ការនាំចេញ បានកើនឡើង 2.4.0% ដែលមានទឹកប្រាក់សរុប ¥5.941 trillion និងការនាំចូល បានថយចុះ -3.6% ដែលមានទឹកប្រាក់ ¥6.365 trillion។*

*ការនាំចេញទៅសហរដ្ឋអាមេរិក បានកើន 14.3% ដែលមានទឹកប្រាក់ ¥1.215 trillion ចំណែកការនាំចូលវិញ បានកើន 0.5% ស្មើនឹង ¥ 583.98 billion។*

*រីឯ ការធ្វើពាណិជ្ជកម្មជាមួយប្រទេសចិនវិញ ការនាំចេញបានថយចុះ -17.3% ស្មើនឹង ¥888.89 billion និងការនាំចូល កើនឡើង 39.4% ដែលមានចំនួន ¥1.787 trillion បើធៀបនឹងរយៈពេលដូចគ្នា នៃឆ្នាំ២០១៤ ។*

*ការនាំចេញទៅកាន់សហគមន៍អឺរ៉ុប បានកើន 1.9% ស្មើនឹង ¥ 621.11 billion ប៉ុន្តែ ការនាំចូលវិញ បានធ្លាក់ចុះ -3.8% ដែលមានទំហំទឹកប្រាក់ ¥ 623.38 billion។*

### ៣-សកម្មភាពការងារ:

*- ថ្ងៃទី០២ មីនា : បានជួបប្រជុំជាមួយតំណាង Kura Law & Patent Office ពិភាក្សាលើការការពារ Patent និងការធ្វើពាណិជ្ជកម្មនៅកម្ពុជា។*

*- ថ្ងៃទី៥-៦ មីនា: បានចូលរួមកិច្ចប្រជុំ Council Director Meeting លើកទី ៣៤ រៀបចំដោយ ASEAN-Japan Centre ដើម្បីអនុម័តថវិកាសម្រាប់ FY2015។*

*- ថ្ងៃទី១០ មីនា : បានចូលរួមក្នុងពិធីជួបជុំប្រចាំឆ្នាំរបស់ក្រសួងហិរញ្ញវត្ថុជប៉ុន។*

*- ថ្ងៃទី១២ មីនា : បានចូលរួមសិក្ខាសាលាស្តីពី Inequality: What has been happening, why does it matter, and when can be done? សហការរៀបចំ ដោយសាកលវិទ្យាល័យ Hitotsubashi & Regional Office for Asia and the Pacific of IMF។*

*-ថ្ងៃទី១៧មីនា: បានអមឯកឧត្តមឯកអគ្គរាជទូតជួបប្រជុំជាមួយតំណាងក្រុមហ៊ុន FUJITSU LIMITED ពិភាក្សាពីការចូលរួមរបស់ស្ថានទូតក្នុងវេទិការបស់ FUJITSU ដែលគ្រោងរៀបចំនៅក្នុងអំឡុង ១៣ ឧសភា ២០១៥ ខាងមុខ និងបានចូលរួមកម្មវិធីផ្លាស់ប្តូរសហគ្រិនជាស្ត្រី និងកាលានុវត្តភាពធុរកិច្ច រៀបចំដោយ Asia Leaders Association។*

- ថ្ងៃទី១៨ មីនា ៖ បានចូលរួមការជួបជុំលើប្រធានបទ "Stop Racism" & "Stop Hate Speech" រៀបចំដោយសភាជាន់ខ្ពស់ (Diet) ក្នុងគោលបំណងលប់បំបាត់ការរើសអើងជាតិសាសន៍។

- ថ្ងៃទី១៩ មីនា ៖ បានចូលរួមក្នុង Symposium entitled "Evolving source of Value-added: Good-Jobs, Bad-Jobs? រៀបចំដោយវិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ JETRO។

- ថ្ងៃទី២៣ មីនា៖ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយរបស់ក្រុមហ៊ុន TOYOTA ដែលបានដាក់បង្ហាញម៉ូដែលរថយន្តម៉ាក TOYOYA MIRAI ស៊េរីថ្មី (Eco-Friendly Car) ជាមួយនឹងបច្ចេកវិទ្យាថ្មី។

- ថ្ងៃទី២៥ មីនា៖ បានជួបជាមួយតំណាង JICA ស្នើសុំ Courtesy Call មកស្ថានទូត ដើម្បីជូនព័តមានពីកម្មវិធីបណ្តុះបណ្តាលថ្មីលើការរុករករ៉ែ។

- ថ្ងៃទី២៧ មីនា៖ បានចូលរួមក្នុងកិច្ចប្រជុំ Executive Board Meeting រៀបចំដោយ AJC ដើម្បីពិនិត្យមើលលើគម្រោងនានា (ពាណិជ្ជកម្ម-វិនិយោគ និងទេសចរណ៍) សម្រាប់អនុវត្តឆ្នាំ២០១៥។

- ថ្ងៃទី២៩ មីនា ៖ បានចូលរួមក្នុង TOSHIBA YOUTH CLUB ASIA រៀបចំដោយ National Olympic Memorial Youth Center ដោយមានការគាំទ្រពី TOSHIBA International Foundation និង TOSHIBA THAI Foundation និងសម្របសម្រួលដោយ ASCOJA, ASIA International។

- ថ្ងៃទី៣០ មីនា ៖ បានរួមក្នុង Cherry Blossoms Reception រៀបចំដោយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទជប៉ុន។

- ថ្ងៃទី៣១ មីនា ៖ បានរួមក្នុង Cabinet Briefing on Japan Economy រៀបចំដោយខុទ្ទកាល័យនាយករដ្ឋមន្ត្រី និងបានចូលរួមក្នុងពិធីលារបស់អគ្គលេខាធិការ AJC។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ និងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំបាទ។

បានឃើញ និងគោរពជូន
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជា
របាយការណ៍ដ៏ខ្ពង់ខ្ពស់។

**ហោ មុនីរ័ត្ន**

អ្នកធ្វើរបាយការណ៍
ទីប្រឹក្សាពាណិជ្ជកម្ម

**ឡៅ ងួន អេង**

**__ចម្លងជូន:__**
-ក្រសួងពាណិជ្ជកម្ម
-ឯកសារ-កាលប្បវត្តិ